**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៦៣២.....សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៤/៨៦១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៤ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ និងអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៦/៥៥៨ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៥ ស្តីពីការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦ ស្ដីពីតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៧៧១ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ស្ដីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦២១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦ ស្ដីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៧៧២ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ស្ដីពីការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៣៩ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលភារកិច្ច និងផ្ទេរភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ០១២ សហវ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការប្រគល់សិទ្ធិ
- ប្រកាសលេខ ១០៥៥ សហវ.ប្រក ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលភារកិច្ច និងផ្ទេរភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្ដីសម្រេចលេខ ០១៤ សហវ ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ២០១៥ ស្ដីពីការប្រគល់ភារកិច្ចបន្ថែមបណ្ដោះអាសន្នជូនឯកឧត្ដម វង់ សណ្ដាប់ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.- កំណត់ភារកិច្ចតាមក្របខ័ណ្ឌការងារជូនអនុរដ្ឋលេខាធិការ ដូចតទៅ :**

ក.ឯកឧត្ដម **ញាណ ឡេង** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោមៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងធនធានទឹក និងឧតុនិយម ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ធំ និងខេត្តឧត្ដរមានជ័យ ។

៣- ការងារដោយឡែកៈ ជួយរដ្ឋលេខាធិការទទួលបន្ទុកការងារអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, ទទួលបន្ទុកជាប្រធានគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, ជួយការងាររដ្ឋលេខាធិការទទួលបន្ទុកការងារគោលនយោបាយចំណាយលើកិច្ចការហិរញ្ញកិច្ច និងជួយកិច្ចការផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ខ.ឯកឧត្ដម **សួន ម៉េងគា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោមៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងរ៉ែ និងថាមពល និងក្រសួងយុត្តិធម៌ ។

២- ការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត: គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពត ។

៣- ការងារដោយឡែក: ជួយការងារទេសរដ្ឋមន្ត្រីក្នុងការគ្រប់គ្រងការទារបំណុលក្នុងវិស័យរ៉ែ, គ្រប់គ្រងការងារពាក់ព័ន្ធនឹងវិស័យព្រៃឈើ និងគម្រោងវិស័យអគ្គិសនី, ជួយការងាររដ្ឋលេខាធិការពាក់ព័ន្ធក្នុងផ្នែកគោលនយោបាយចំណូលមិនមែនសារពើពន្ធ និងជួយកិច្ចការ ដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

គ.ឯកឧត្តម **ឆាន់ ចឡុន**: អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម:

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ: គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ក្រសួងពាណិជ្ជកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត: គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ ។

៣- ការងារដោយឡែក: ការងារអភិវឌ្ឍន៍តំបន់ព្រះវិហារ, ជួយការងាររដ្ឋលេខាធិការទទួលបន្ទុកគោល-នយោបាយអភិបាលកិច្ចសាជីវកម្ម គណនេយ្យ សវនកម្ម និងអធិការកិច្ច និងជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ឃ.ឯកឧត្តម **សុខ សារាវុឌ្ឍ** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម:

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ: គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត: គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង ។

៣- ការងារដោយឡែក: ជួយការងាររដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, ការងារកែទម្រង់ប្រព័ន្ធថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការងារគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងជួយកិច្ចការដទៃទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ង.ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម:

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ: គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមានក្រសួងព័ត៌មាន និងក្រុមប្រឹក្សាធម្មនុញ្ញ ។

២- ការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត: គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង ។

៣- ការងារដោយឡែក: ជួយការងារទេសរដ្ឋមន្ត្រី ក្នុងឋានៈជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ជួយសម្របសម្រួលការងារគោលនយោបាយដែលមានភាពប្រទាក់ក្រឡាគ្នា ដែលរួមមាន គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ, ជួយការងាររដ្ឋលេខាធិការពាក់ព័ន្ធលើការងារគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ, ការងារមហា-

អនុតំបន់ទន្លេមេគង្គ (GMS), បំពេញមុខងារជាអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុកម្ពុជានៅក្នុងកិច្ចប្រជុំអនុរដ្ឋ-មន្ត្រីហិរញ្ញវត្ថុអាស៊ាន និងជួយកិច្ចការផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ច. លោកជំទាវ **កែវ ចរិយា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម:

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ: គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងក្រសួងកិច្ចការនារី ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត: គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកណ្ដាល ។

៣- ការងារដោយឡែក: ការងារយេនឌ័រ, ជួយការងារគណៈកម្មាធិការឯកជនភាវូបនីយកម្ម និងជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ឆ. ឯកឧត្តម **ទង់ សណ្ដាប់** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម:

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ: គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ក្រសួងបរិស្ថាន និងអង្គភាពប្រឆាំងអំពើពុករលួយ ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ: គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តមណ្ឌលគិរី និងខេត្តរតនគិរី ។

៣- ការងារដោយឡែក: ជួយការងារទេសរដ្ឋមន្ត្រីលើការងារគ្រប់គ្រងគ្រោះមហន្តរាយ និងជាសេនាធិ-ការរបស់ទេសរដ្ឋមន្ត្រីសម្រាប់គម្រោងសាច់ប្រាក់សម្រាប់ពលកម្ម (Cash for Work) ដោយធ្វើការសម្របសម្រួលជាមួយថ្នាក់ដឹកនាំរបស់ក្រសួងដែលមានការពាក់ព័ន្ធ, ជួយសម្របសម្រួលការងារគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ, ទទួលបន្ទុកជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា និងជួយកិច្ចការផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ជ. ឯកឧត្តម **ហែម វណ្ណឌី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម:

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈអភិបាលហិរញ្ញវត្ថុ: គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ក្រសួងមុខងារសាធារណៈ និងអាជ្ញាធរសវនកម្មជាតិ ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត: គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកោះកុង ។

៣- ការងារដោយឡែក: ជួយការងាររដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល, គ្រប់គ្រងការងារតំបន់ត្រីកោណ ACMEC, CLMV, CLV, ESCAP និងជួយកិច្ចការផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ឈ. ឯកឧត្តម **ឈន សុភាព** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម:

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ: គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួង ស្ថាប័ន រួមមាន ក្រសួងវប្បធម៌ និងវិចិត្រ-សិល្បៈ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ។

២- គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តសៀមរាប ។

៣- ការងារដោយឡែកៈ ជួយទេសរដ្ឋមន្ត្រីក្នុងការងារគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានអង្គរ, តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅអាជ្ញាធរអប្សរា, ជួយការងាររដ្ឋលេខាធិការពាក់ព័ន្ធក្នុងផ្នែកគោលនយោបាយគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លើកលែងសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងជួយកិច្ចការផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ញ.ឯកឧត្តម **ស ថេង** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោមៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងធម្មការ និងសាសនា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តស្វាយរៀង ។

៣- ការងារដោយឡែកៈ ជួយទេសរដ្ឋមន្ត្រីលើការងារបង្ក្រាបការរត់គេចពន្ធ, ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ដ.ឯកឧត្តម **ពេជ្រ សម្បត្តិ** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោមៈ

១- ការងារគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

២- ការគ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម ។

៣- ការងារដោយឡែកៈ ជួយរដ្ឋលេខាធិការពាក់ព័ន្ធនឹងការងារសម្របសម្រួលគោលនយោបាយសហគ្រាសធុនតូច និងមធ្យម និងជួយកិច្ចការផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ឋ.ឯកឧត្តម **ហ៊ីង សុវណ្ណា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោមៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

២- គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ ។

៣- ការងារដោយឡែកៈ ជួយការងាររដ្ឋលេខាធិការទទួលបន្ទុកការងារលទ្ធកម្មសាធារណៈ និងជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ឌ.ឯកឧត្តម **អៀង ស៊ុនលី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោមៈ

១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

២- គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តតាកែវ និងខេត្តកែប ។

៣- ការងារដោយឡែកៈ ជួយការងាររដ្ឋលេខាធិការពាក់ព័ន្ធក្នុងផ្នែកគោលនយោបាយគ្រប់គ្រងសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងជួយកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ឃ. ឯកឧត្តម **ម៉ូ រតនា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖
- ១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ៖ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងទេសចរណ៍ ។
- ២- ការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត៖ គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តពោធិ៍សាត់ ។
- ៣- ការងារដោយឡែក៖ ជួយរដ្ឋលេខាធិការពាក់ព័ន្ធនឹងការងារសម្របសម្រួលគោលនយោបាយអភិវឌ្ឍន៍វិស័យឯកជន ។

ណ. ឯកឧត្តម **ចាន់ សុធី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖
- ១- ជួយការងារទេសរដ្ឋមន្ត្រីលើការងាររៀបចំ, ប្រមូលសរុប, ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកា,
- ២- ជួយការងាររដ្ឋលេខាធិការទទួលបន្ទុកគោលនយោបាយចំណាយលើការងារថវិកា រួមទាំងការជំរុញអនុវត្តថវិកាតាមកម្មវិធី និងការរៀបចំថវិកា,
- ៣- ទទួលបន្ទុកសម្របសម្រួល ពិនិត្យ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងលើរាល់ការងារគោលនយោបាយ និងបច្ចេកទេសរបស់អគ្គនាយកដ្ឋានថវិកា និងជួយកិច្ចការដទៃទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ត. ឯកឧត្តម **ផាន់ ផល្លា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖
- ១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ៖ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- ២- គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត៖ គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តក្រចេះ និងខេត្តប៉ៃលិន ។
- ៣- ការងារដោយឡែក៖ ជួយការងារទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជួយការងាររដ្ឋលេខាធិការពាក់ព័ន្ធនឹងផ្នែកគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងជួយកិច្ចការដទៃទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ថ. ឯកឧត្តម **ហ៊ែល ចំរើន** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖
- ១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ៖ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។
- ២- គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត៖ គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ ។
- ៣- ការងារដោយឡែក៖ ជួយទេសរដ្ឋមន្ត្រីក្នុងការងារនីតិកម្ម និងក្រុមប្រឹក្សានីតិកម្ម និងជួយកិច្ចការដទៃទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ទ. ឯកឧត្តម **ឯក ទីរដ្ឋ** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖
- ១- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុ៖ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងអភិវឌ្ឍន៍ជនបទ ។
- ២- គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត៖ គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រៃវែង និងខេត្តបន្ទាយមានជ័យ ។
- ៣- ការងារដោយឡែក៖ ជួយកិច្ចការផ្សេងៗតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

**ប្រការ ២.-** អនុរដ្ឋលេខាធិការ អាចជួយទេសរដ្ឋមន្ត្រី ក្នុងការបំពេញកិច្ចការផ្សេងៗ ទៅតាមការប្រគល់សិទ្ធិរបស់ទេសរដ្ឋមន្ត្រី ។

**ប្រការ ៣.-** ភារកិច្ច សិទ្ធិអំណាច នីតិវិធី និងរបៀបរបបបំពេញការងារប្រចាំថ្ងៃ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ៦២១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦ ។

**ប្រការ ៤.-** ប្រកាសនេះត្រូវមានអានុភាពអនុវត្តជំនួសប្រកាស និងសេចក្តីសម្រេចដូចខាងក្រោមៈ

- ប្រកាសលេខ ៧៧២ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៤ ពីការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ០១២ សហវ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិ
- ប្រកាសលេខ ១០៥៥ សហវ.ប្រក ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលភារកិច្ច និងផ្ទេរភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចលេខ ០១៤ សហវ ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ២០១៥ ស្តីពីការប្រគល់ភារកិច្ចបន្ថែមបណ្តោះអាសន្នជូនឯកឧត្តម វង់ សណ្តាប់ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.-** ប្រកាស និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃប្រកាស និងសេចក្តីសម្រេចដែលត្រូវបានជំនួសក្នុងប្រការ ៤ ខាងលើ ត្រូវបន្តអានុភាពគតិយុត្ត រហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស តាមការកំណត់របស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៦.-** រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវ ដែលមានរាយនាមក្នុងប្រការ ១ នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក គ្រប់អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងគ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៦

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

*កន្លែងទទួល :*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ